# <u>រោងចក្រផលិតទឹកស្អាតធំមួយនៅភ្នំពេញត្រូវបានសាងសង់រួចរាល់ ៧៧ភាគរយ ហើយគ្រោងនឹងបញ្ចប់នៅចុងឆ្នាំ២០១៦</u>




**(ភ្នំពេញ)៖** រោងចក្រផលិតទឹកស្អាតនិរោធន៍ជំហានទី២ នៅសង្កាត់និរោធន៍ ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ ពេលនេះត្រូវបានសាងសង់រួចរាល់ ៧៧ភាគរយហើយ ដោយគ្រោងនឹងបញ្ចប់ នៅចុងឆ្នាំ២០១៦ ឬដើមឆ្នាំ២០១៧ ខាងមុខនេះ។

លោក ស៊ឹម ស៊ីថា អគ្គនាយករដ្ឋាករទឹកស្វយ័តក្រុងភ្នំពេញ បានប្រាប់ភ្នាក់ងារព័ត៌មាន Fresh News ឱ្យដឹងថាពេលនេះ រោងចក្រផលិតទឹកស្អាតនិរោធន៍ជំហានទី២នេះ នឹងបញ្ចប់ត្រូវសាងសង់រួចជាស្ថាពរ នៅចុងឆ្នាំ២០១៦ ឬដើមឆ្នាំ២០១៧ ខាងមុខនេះ ។

នៅព្រឹកថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០១៥នេះ លោកទេសរដ្ឋមន្ត្រី ចម ប្រសិទ្ធ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម និងសិប្បកម្ម បានដឹកនាំគណៈប្រតិភូមួយក្រុម ដើម្បីចុះត្រួតពិនិត្យមើលដំណើរការនៃរោងចក្រផលិតទឹកស្អាតមួយនេះ។ លោកក៏បានជំរុញទឹកចិត្តដល់ការសាងសង់រោងចក្រទឹកស្អាតនេះ ឱ្យបានរួចរាល់ដូចគម្រោងផងដែរ។

រោងចក្រផលិតទឹកស្អាតនិរោធន៍ជំហានទី២ មានសមត្ថភាពផលិតទឹក ១៣០.០០០ម៉ែត្រគូបក្នុងមួយថ្ងៃ ដែលចាប់ផ្ដើមសាងសង់កាលពីថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៤ ។ ការសាងសង់រោងចក្រនេះ ប្រើកម្ចីវិនិយោគពីទីភ្នាក់ងារបារាំងសម្រាប់ការអភិវឌ្ឍ (AFD) ប្រមាណ២៦លានដុល្លារ និងថវិកាវិភាគទាន១២លានដុល្លារ។









15